នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Jan-2016, 10:54
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសដ
**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល
**ថ្ងៃដាក់** : ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ:** អមដោយ **ឧបសម្ព័ន្ធសម្ងាត់បំផុត ២**
**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:** សាធារណៈ/Public
**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**
**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**
**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**
**ហត្ថលេខា:**

---

## ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារមួយចំនួន ពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤-D193/61

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele MUMBA

**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**
លោកស្រី ទូច វល័ក្ស
លោក Calvin SAUNDERS

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Michael BOHLANDER

ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

## I. ការដាក់បង្ហាញ

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") សូមដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួនហាសិបមួយ(៥១) ដែលបានទទួលយករួចហើយនៅក្នុងសំណុំរឿង០០៤ ដោយបំពេញទៅតាមកាតព្វកិច្ចនៃការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង០០២ ("សម្ភារៈ")។ សម្ភារៈទាំងអស់សុទ្ធតែបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធសម្ងាត់បំផុតទាំងពីរ គឺ **ឧបសម្ព័ន្ធ ក** និង **ឧបសម្ព័ន្ធ ខ**។

2. សហព្រះរាជអាជ្ញា សូមស្នើការអនុញ្ញាតដាក់បង្ហាញសម្ភារៈទាំងនេះ ដែលបានបញ្ចូលទៅក្នុងសំណើសុំដាក់បង្ហាញនេះ តាមរយៈសំណើចំនួនប្រាំ (សំណើទាំងប្រាំ រួមគ្នាហៅថា "សំណើ") ដែលបានដាក់ជូនទៅសហចៅក្រមស៊ើបអង្កេត ("សចស") នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥[1], ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥[2], ថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥[3], ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥[4] និងថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥[5]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (សចសអ) បានផ្តល់ការអនុញ្ញាតឲ្យដាក់បង្ហាញសំណើទាំងនេះ ទាក់ទងនឹងឯកសារដែលបច្ចុប្បន្នបាននឹងកំពុងដាក់បង្ហាញនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ("សេចក្តីសម្រេចរបស់ សចសអ")[6]។ សេចក្តីសម្រេចនោះ ត្រូវបានចែកជូនដល់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃចេញ។

---

[1] សំណុំរឿង០០៤-**D193/29** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅខែកក្កដា ឆ្នាំ២០១៥ សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២, ២៩ កក្កដា ២០១៥។

[2] សំណុំរឿង០០៤-**D193/42** សំណើខែកញ្ញា ឆ្នាំ២០១៥ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿងលេខ ០០៤ ទៅក្នុងសំណុំរឿងលេខ ០០២, ២៥ កញ្ញា ២០១៥។

[3] សំណុំរឿង០០៤-**D193/45** សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ៧ តុលា ២០១៥។

[4] សំណុំរឿង០០៤-**D193/46** សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ១៦ តុលា ២០១៥។

[5] សំណុំរឿង០០៤-**D193/48** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ២១ តុលា ២០១៥។

[6] សំណុំរឿង០០៤-**D193/61** ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/29, D193/35, D193/38, D193/39, D193/42, D193/45, D193/46 និង D193/48, ១៧ ធ្នូ ២០១៥ ("សេចក្តីសម្រេច")។

3. សហព្រះរាជអាជ្ញា បានកត់សម្គាល់ទៅលើសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងកាតព្វកិច្ចក្នុងការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង០០២/០២ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥[7]។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់បង្ហាញជូនអង្គជំនុំជម្រះ និងភាគី នូវឯកសារដោះបន្ទុកពីសំណុំរឿង០០៣ និង០០៤ ទៅតាមមូលដ្ឋានមួយដែលត្រូវធ្វើជាបន្តបន្ទាប់ រហូតដល់ពេលបញ្ចប់សំណុំរឿង០០២/០២[8]។ អង្គជំនុំជម្រះក៏បានបង្គាប់ផងដែរឱ្យសហព្រះរាជអាជ្ញាដាក់បង្ហាញគ្រប់កំណត់ហេតុរបស់បុគ្គលម្នាក់ៗទាំងអស់នៃសំណុំរឿង០០៣ និង០០៤ ដែលបានស្នើឱ្យមកបំភ្លឺនៅក្នុងសំណុំរឿង០០២/០២[9]។ អង្គជំនុំជម្រះក៏បានធ្វើការសម្រេចបន្ថែមថា សម្ភារៈបន្ថែមណាមួយនៃសំណុំរឿង០០៣ និង០០៤ ដែលសហព្រះរាជអាជ្ញាមានបំណងចង់ដាក់ជូនស្របតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង គួរត្រូវបានដាក់ក្នុងពេលវេលានៃការដាក់ពាក្យសុំដែលមានសម្អាងហេតុ អនុលោមតាមវិធាន៨៧(៤)[10]។

4. សហព្រះរាជអាជ្ញា ក៏ធ្វើការកត់សម្គាល់ផងដែរអំពីការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ លើសំណើរបស់ នួន ជា ទាក់ទងនឹងកាតព្វកិច្ចក្នុងការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង០០២/០១[11]។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូល បានបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់បង្ហាញជូនអង្គជំនុំជម្រះតុលាការកំពូល និងគូភាគី នូវភ័ស្តុតាងដែល (i) បានផ្តល់ដោយសាក្សីណាម្នាក់ដែលធ្លាប់ធ្វើការងារដោយផ្ទាល់ជាមួយ រស់ ញឹម ឬ (ii) ពាក់ព័ន្ធនឹងការប្រឆាំងនឹង ប៉ុល ពត និង នួន ជា នៅភូមិភាគពាយ័ព្យ នៅមុនថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

---

7 **E363/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា, ២២ តុលា ២០១៥។

8 *ដដែលដូចខាងលើ,* កថាខណ្ឌ២១-២៤, សេចក្តីសម្រេចបញ្ចប់។

9 *ដដែលដូចខាងលើ,* កថាខណ្ឌ២៥-២៧, សេចក្តីសម្រេចបញ្ចប់។

10 *ដដែលដូចខាងលើ,* កថាខណ្ឌ២៨-៣០, សេចក្តីសម្រេចបញ្ចប់។

11 **F2/4/2** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១, ១៦ មីនា ២០១៥, សេចក្តីសម្រេចបញ្ចប់។

5. សហព្រះរាជអាជ្ញាធ្លាប់ដាក់បង្ហាញពីមុននូវកំណត់ហេតុនៃការស្តាប់ចម្លើយចំនួនបួន កំណត់ហេតុនៃកិច្ចស៊ើបសួរចំនួនមួយ និងឧបសម្ព័ន្ធមួយ ដែលបានអនុញ្ញាតឲ្យដាក់បង្ហាញតាមសេចក្តីសម្រេចរបស់ សចសអ ជូនអង្គជំនុំជម្រះសាលាដំបូង[12]។ ហេតុនេះ សហព្រះរាជអាជ្ញាសូមដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយ និងកំណត់ហេតុនៃកិច្ចស៊ើបសួរដែលនៅសល់ដែលបានអនុញ្ញាតសម្រាប់ការដាក់បង្ហាញតាមសេចក្តីសម្រេចរបស់ សចសអ ដែល៖ មានសម្ភារៈដោះបន្ទុក រួមមានកំណត់ហេតុនៃការស្តាប់ចម្លើយរបស់បុគ្គលម្នាក់ ដែលបានស្នើឲ្យមកបំភ្លឺដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង០០២ និង/ឬ បានបំពេញតាមប្រភេទនៃភ័ស្តុតាងដូចបានបង្គាប់ឲ្យដាក់បង្ហាញដោយអង្គជំនុំជម្រះតុលាការកំពូល[13]។ ពាក្យសុំដែលអនុលោមតាមវិធាន៨៧(៤) និងការដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានអនុញ្ញាតតាមសេចក្តីសម្រេចរបស់ សចសអ នឹងដាក់តាមក្រោយក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន។

6. ដើម្បីតម្លាភាព សហព្រះរាជអាជ្ញាសូមផ្តល់សេចក្តីពិស្តារមួយចំនួនអំពីការអនុវត្តសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា ភ័ស្តុតាងដោះបន្ទុកត្រូវបានកំណត់និយមន័យថា "សម្ភារៈទាំងឡាយ ដែលតាមការយល់ដឹងពិតប្រាកដរបស់សហព្រះរាជអាជ្ញា អាចបញ្ជាក់ពីនិរទោស ឬបន្ថយពិរុទ្ធភាពរបស់ជនជាប់ចោទ ឬអាចមានផលប៉ះពាល់ទៅលើភាពជឿជាក់នៃភ័ស្តុតាងចោទប្រកាន់"[14]។ ប្រសិនបើ សហព្រះរាជអាជ្ញាបានដាក់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីណាម្នាក់ទៅក្នុងសំណុំរឿង ហើយសាក្សីរូបនោះមិនត្រូវបានស្នើឲ្យមកបំភ្លឺទេ នោះសហព្រះរាជអាជ្ញានឹងពិចារណាលើកំណត់ហេតុផ្សេងទៀតរបស់សាក្សីរូបនេះថាមានផលប៉ះពាល់ចំពោះភាពជឿជាក់ទៅលើភ័ស្តុតាងដាក់បន្ទុក ប្រសិនបើ៖ (i) សាក្សីកែ ឬ ប្តូរកំណត់ហេតុនៅក្នុងភ័ស្តុតាងចំពោះបញ្ហាដែលពាក់ព័ន្ធ ឬ (ii) សាក្សីបន្ទាបតម្លៃនៃភាពជឿជាក់របស់គាត់

---

12 **E319/38** ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៃឯកសារសំណុំរឿង០០៤ ចំនួនមួយ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ អនុលោមតាមសំណុំរឿង០០៤ - D193/61។ **E319/39** ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារមួយចំនួនពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤ - D193/61, ៨ មករា ២០១៦។

13 *សូមមើល* កថាខណ្ឌ ៤ ខាងលើ។

14 **E363/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា, ២២ តុលា ២០១៥, កថាខណ្ឌ២៣។ សូមមើលផងដែរ កំណត់សម្គាល់ជើងទំព័រលេខ៥៦ កត់សម្គាល់ថា ស្ថិតនៅក្នុង អ.វ.ត.ក, ភ័ស្តុតាងដាក់បន្ទុក គឺជាពាក្យដែលសមរម្យជាង "ភ័ស្តុតាងចោទប្រកាន់"។

ជាទូទៅ។ ប្រសិនបើ សហព្រះរាជអាជ្ញាគ្រាន់តែបានបង្ហាញកំណត់ហេតុស្ដាប់ចម្លើយសាក្សីម្នាក់ ឬកំណត់ហេតុរបស់បុគ្គលណាម្នាក់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមិនបានស្នើសុំឱ្យមកបំភ្លឺ ហើយកំណត់ហេតុនោះមិនបានស្នើសុំដាក់ទៅក្នុងភស្តុតាង ឬកំណត់ហេតុផ្សេងទៀតពីបុគ្គលនោះចូលជាភស្តុតាង នោះសហព្រះរាជអាជ្ញាក៏មិនពិចារណាអំពីភាពមិនស៊ីសង្វាក់គ្នារវាងកំណត់ហេតុនានាដែលមានលក្ខណៈគ្រប់គ្រាន់ សម្រាប់កំណត់អំពីឋានៈនៃការដោះបន្ទុកដោយផ្អែកលើតែមូលដ្ឋាននោះប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាក៏មានបំណងធ្វើការកត់សម្គាល់ផងដែរថាសហព្រះរាជអាជ្ញាមិនពិចារណាលើភស្តុតាងណាដែលកម្មាភិបាលត្រូវបានគេផ្ដន្ទាទោសចំពោះអំពើរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំថាជាការដោះបន្ទុកដែរ ដូចដែលដីកាដំណោះស្រាយមិនបានចោទប្រកាន់ជនជាប់ចោទនឹងបទល្មើសរំលោភសេពសន្ថវៈដែលបានប្រព្រឹត្តក្រៅវិសាលភាពការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[15]។

7. ក្នុងឧបសម្ពន្ធអមមកជាមួយនេះ សហព្រះរាជអាជ្ញាបានបញ្ជាក់នៅក្នុងជួរឈរមួយក្រោមចំណងជើងថា "ប្រភេទដាក់បង្ហាញ" ដែលជាមូលហេតុសម្រាប់ការដាក់បង្ហាញរបស់ឯកសារនោះ។ ដើម្បីជៀសវាងការដាក់បង្ហាញច្រំដែលទៅកាន់ភាគីនោះ សហព្រះរាជអាជ្ញាបានពិនិត្យឡើងវិញជាមួយគ្នានូវសម្ភារៈនោះ ដោយពិចារណាលើគោលការណ៍ណែនាំស្ដីពីការដាក់បង្ហាញឯកសាររបស់អង្គជំនុំជម្រះតុលាការកំពូល និងបានបញ្ជាក់នៅក្នុងជួរឈរនៃ "ប្រភេទដាក់បង្ហាញ" ត្រង់កន្លែងដែលឯកសារត្រូវបានដាក់បង្ហាញអនុលោមតាមសេចក្ដីណែនាំទាំងនោះ ដែលអាចនឹងមិនត្រូតគ្នាក្នុងរាល់ករណី តាមលក្ខខណ្ឌដែលបានគូសបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូង។

8. អង្គជំនុំជម្រះសាលាដំបូងបានណែនាំថា ជាដំបូង សហព្រះរាជអាជ្ញាត្រូវដាក់សំណើសុំបង្ហាញរបស់ខ្លួនទៅអង្គជំនុំជម្រះ ដោយប្ដឹងពីភស្តុតាងដែលខ្លួនចង់ដាក់បង្ហាញ បន្ទាប់មកទើបដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំឱ្យទទួលយកឯកសារណាមួយ ទុកជាការអនុម័តសម្រាប់ការដាក់បង្ហាញឯកសារ[16]។

---

[15] **E306** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ស្ដីពី "ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់", ២៥ មេសា ២០១៤, កថាខណ្ឌ៣ ដកស្រង់ដីកាដំណោះស្រាយ D427 ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ១៤២៦-១៤២៩។

[16] **E127/7/1** ព័ត៌មានពាក់ព័ន្ធនឹងកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៃសំណុំរឿង០០៣ និង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង ០០២, ១៦ សីហា ២០១៣, កថាខណ្ឌ២។

9. អង្គជំនុំជម្រះសាលាដំបូង ធ្លាប់បានបង្គាប់ពីមុនថា គ្រប់ការដាក់បង្ហាញឯកសារទាំងអស់ ពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២ គប្បីដាក់ និងជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងជាបណ្តោះអាសន្នដោយឈរលើមូលដ្ឋានសម្ងាត់បំផុត និងថាបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់ចំពោះឯកសារនោះថាតើ គប្បីដាក់ចំណាត់ថ្នាក់ឡើងវិញថា សម្ងាត់ ឬក៏អត់[17]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល អំពីឯកសារដែលមាននៅក្នុង **ឧបសម្ព័ន្ធ ក និងឧបសម្ព័ន្ធ ខ** ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត។

10. ការផ្តល់សិទ្ធិឲ្យដាក់បង្ហាញឯកសារក្នុង**ឧបសម្ព័ន្ធ ក** គឺត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវមួយចំនួនខាងក្រោមដែលកំណត់ដោយ សចសអ ដូចតទៅ៖[18]

ក. សម្ភារៈទាំងអស់ត្រូវចាត់ទុកជាសម្ងាត់។

ខ. ក្នុងករណីដែលសម្ភារៈត្រូវបានទទួលយកធ្វើជាភស្តុតាងនៅក្នុសំណុំរឿង០០២/០២ សម្ភារៈទាំងនោះត្រូវចាត់ទុកជាសម្ងាត់។

គ. សម្ភារៈទាំងនោះមិនត្រូវផ្សព្វផ្សាយឲ្យលើសពីបុគ្គលទាំងឡាយដែលបានកំណត់អត្តសញ្ញាណយ៉ាងជាក់ច្បាស់នៅក្នុងលក្ខខណ្ឌតម្រូវនានាដែលមានចែងនៅក្នុងនោះទេ។

ឃ. ក្នុងករណីដែលមានសាក្សីនានា ដែលឯកសារផ្សេងៗរបស់ពួកគាត់ត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញនៅក្នុង **ឧបសម្ព័ន្ធ ក** ត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម ពួកគាត់អាចធ្វើដូច្នេះបាននៅក្នុងវគ្គសវនាការសាធារណៈ ឲ្យតែឈ្មោះ និងព័ត៌មានកំណត់អត្តសញ្ញាណផ្សេងៗរបស់ពួកគាត់ ត្រូវបានរក្សាទុកជាសម្ងាត់ ហើយពួកគាត់ត្រូវបានកំណត់អត្តសញ្ញាណតែដោយរហស្សនាមដែលបានដាក់ សម្រាប់ក្នុងសំណុំរឿង០០២/០២ប៉ុណ្ណោះ។

---

17 **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ឆ្នាំ២០១២, ទំព័រ១។

18 សេចក្តីសម្រេច, កថាខណ្ឌ៣២។

ង. សម្ភារៈដែលបានផ្តល់ឱ្យ ដោយអនុលោមតាម **ឧបសម្ព័ន្ធ ក** មិនត្រូវផ្សព្វផ្សាយដល់សាធារណជនឡើយ ទោះជាក្នុងទម្រង់ណាក្តី ឬតាមប្រព័ន្ធព័ត៌មានបែបណាក៏ដោយ ឱ្យលើសពីភស្តុតាងដែលបានបង្ហាញនៅក្នុងវគ្គសវនាការសាធារណៈនោះឡើយ។

ច. ភាគីណាក៏ដោយ ក្រុមមេធាវីការពារក្តី ឬបុគ្គលដទៃទៀត ដែលត្រូវអាន លើកយោង ឬបើមិនដូច្នោះទេ ប្រើប្រាស់ឯកសារណាមួយក្នុងចំណោមឯកសារនានា ដែលបានដាក់បង្ហាញនៅក្នុង **ឧបសម្ព័ន្ធ ក** ត្រូវកំណត់អត្តសញ្ញាណសាក្សីនានា តែដោយរហស្សនាមដែលបានដាក់ សម្រាប់ក្នុងសំណុំរឿង០០២/០២ និងត្រូវប្រើប្រាស់តែការរៀបរាប់ផ្សេងៗ ដែលបានគណនាសមហេតុសមផលប៉ុណ្ណោះ ដើម្បីចៀសវាងនូវការកំណត់អត្តសញ្ញាណសាក្សីរូបនោះ តាមរយៈព័ត៌មានដទៃទៀត។

ឆ. សម្ភារៈទាំងនោះត្រូវផ្តល់ជូនទៅមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងពីររូប មេធាវីប្រចាំការរបស់ ខៀវ សំផន (“មេធាវីប្រចាំការ”) និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសំណៅថតចម្លងអេឡិកត្រូនិច។

ជ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់បង្ហាញសម្ភារៈដែលបានផ្តល់ជូនតាមសេចក្តីសម្រេចនេះ ឱ្យទៅតែសមាជិកនៃក្រុមការងាររបស់ពួកគាត់ដែលទទួលបានការងារជាផ្លូវការ តាមវិធាន ២២(៥) និង វិធាន ១២ (៤) *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ជាមួយនឹងកម្មសិក្សាការីដែលត្រូវបានចាត់តាំងជាផ្លូវការប៉ុណ្ណោះ។

ឈ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ចម្លងនូវសំណៅថតចម្លងនៃឯកសារដើមដែលពួកគេបានទទួលឡើយ ក្រៅពីសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងនៃឯកសារនោះដោយសមាជិកនៃក្រុមនានារបស់ខ្លួនដែលត្រូវបានណែនាំ ឬត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់នោះប៉ុណ្ណោះ។

ញ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវរក្សាកំណត់ហេតុស្តីពីសំណៅដែលខ្លួនបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ចម្លងនូវសំណៅថតចម្លងសម្រាប់ប្រើប្រាស់ផ្ទៃក្នុង ក្នុងរបៀបមួយដែលអាចត្រួតពិនិត្យឡើងវិញបាន។

ឃ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីសំណៅគ្មានការអនុញ្ញាតណាមួយនៃសម្ភារៈដែលបានផ្តល់ជូនតាមរយៈ ដីកាសម្រេចនេះ សមាជិករូបនោះត្រូវចាត់គ្រប់វិធានការទាំងអស់ជាបន្ទាន់ ដើម្បីរក្សាការ ពារសុវត្ថិភាព និងប្រគល់សំណៅសម្ភារៈឯកសារនោះជូន សចអ វិញ។ និង

ច. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កម្រិតទាំងនេះ សមាជិករូបនោះ ត្រូវរាយការណ៍អំពីការរំលោភបំពាននោះជូន សចអ។

11. ការអនុញ្ញាតឱ្យដាក់បង្ហាញឯកសារក្នុង**ឧបសម្ព័ន្ធ ខ** គឺស្ថិតក្រោមលក្ខខណ្ឌតម្រូវខាងលើ ប៉ុន្តែ ចំពោះលក្ខខណ្ឌចាប់ពីកថាខណ្ឌ (ឃ) ដល់ (ច) ដែលប្រែប្រួលទៅតាមការដាក់កម្រិតតឹងរឹងជាង ដូចខាងក្រោមនេះ៖

ក. ក្នុងករណីដែលសាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលឯកសារ របស់ខ្លួន ត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញក្នុង**ឧសម្ពន្ធ ខ** ត្រូវបានកោះហៅឱ្យមកផ្តល់ សក្ខីកម្មនោះ ពួកគេត្រូវធ្វើក្នុងសវនាការអសាធារណៈ។

ខ. គ្មានសម្ភារៈណាមួយដែលត្រូវបានផ្តល់ជូនអនុលោមតាម**ឧបសម្ពន្ធ ខ** ត្រូវបានផ្សព្វផ្សាយ ទៅកាន់សាធារណជន ក្នុងទម្រង់ណាមួយ ឬតាមរយៈទម្រង់សារព័ត៌មានណាមួយ ក៏ដោយ ឬត្រូវបានបង្ហាញ ឬយោងទៅកាន់ នៅក្នុងតុលាការជាចំហរក្នុងលក្ខណៈបែប ណាមួយនោះឡើយ និង

គ. ភាគីណាក៏ដោយ ក្រុមមេធាវីការពារក្តី ឬបុគ្គលដទៃទៀត ដែលត្រូវអាន លើកយោង ឬ បើមិនដូច្នោះទេ ប្រើប្រាស់ឯកសារណាមួយក្នុងចំណោមឯកសារនានា ដែលបានដាក់ បង្ហាញ នៅក្នុង **ឧបសម្ព័ន្ធ ខ** ត្រូវស្នើសុំសវនាការអសាធារណៈ មុនពេលធ្វើដូច្នោះ ហើយ ក្នុងករណីណាក៏ដោយត្រូវកំណត់អត្តសញ្ញាណសាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណី តែតាមរយៈរហស្សនាមដែលបានដាក់ សម្រាប់ក្នុងសំណុំរឿង០០២/ ០២ និងត្រូវប្រើប្រាស់តែការរៀបរាប់ផ្សេងៗដែលបានគណនាសមហេតុសមផលប៉ុណ្ណោះ

ដើម្បីចៀសវាងនូវការកំណត់អត្តសញ្ញាណសាក្សីរូបនោះ ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈព័ត៌មានដទៃទៀត[19]។

## II. ដំណោះស្រាយដែលស្នើឡើង

12. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូង ទទួលយក និងទទួលដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២ នូវឯកសារដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ពន្ធ ក** និង **ខ** ដែលឆ្លើយតបទៅនឹងសេចក្តីណែនាំស្តីពីការដាក់បង្ហាញរៀងៗខ្លួន (ដូចបានបញ្ជាក់ក្នុងឧបសម្ព័ន្ធ)៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ | **លោក** **Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |

[19] សេចក្តីសម្រេច, កថាខណ្ឌ៣៤។